សាងសង់និងស្តារផ្លូវជាតិលេខ៦(ថ្នល់កែង-ស្គន់-កំពង់ធំ-សៀមរាប)	486.000	4.050	8 100	81 000	93 150
[illegible]ផ្លូវជាតិលេខ៧៦បេ(តាវែង-អូរកែវ)	486 000	4 050	8.100	81 000	93.150
គម្រោង[illegible]ផ្លូវ[illegible]១៥៧៧បំបែកពីផ្លូវជាតិលេខ៥៧ ត្រង់សេកសក-សំឡូត-ច្រក៤០០ ព្រំដែនកម្ពុជា-ថៃ	141 750	4 050	8 100	60 750	72 900
[illegible]ផ្លូវលេខ[illegible](៧៨អា)ពីបានលុងទៅព្រំប្រទល់កម្ពុជា-ឡាវ	607.500	8 100	12 150	121 500	141 750

ការគ្រប់គ្រងឆ្នាំ២០១៣

តារាង "គ១"

ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

ឈ្មោះគម្រោង	តម្លៃគម្រោង	កម្រិតខ្ទង់វិនិយោគចែកតាមឆ្នាំ			
		២០១៣	២០១៤	២០១៥	សរុប៣ឆ្នាំ
គម្រោងសាងសង់ផ្លូវជាតិលេខ១៧០(កំពង់ចាម-ក្រកោង)	168.868	4.050	8.100	60.750	72.900
គម្រោងស្តារឡើងវិញផ្លូវជាតិលេខ២និងផ្លូវជាតិលេខ២២	121.500	4.050	8.100	8 100	20.250
គម្រោងស្តាបនាផ្លូវពីNR4(ភ្នំស្រួច)កាត់តាមNR3-NR2-ព្រែកប្បាសទៅកោះធំ(NR21)	146.694	8.100	8.100	60 750	76.950
គម្រោងស្តាបនាផ្លូវពីPR១១០(កោះធំ)ទៅកាន់ផ្លូវPR១១៨	62.060	4.050	4.050	20.250	28.350
គម្រោងស្តាបនាផ្លូវពីព្រែកតាម៉ាក់-ល្វាឯម-ពាមរក៍(ផ្លូវជាតិលេខ១១)	198.698	4.050	4.050	60.750	68.850
គម្រោងសាងសង់ស្ពានជាក់ជាង	2.025	810	1.215		2.025
ការអភិវឌ្ឍផែតាមបណ្តោយទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាប	36.397	4.050	12.150	12 150	28.350
កែលំអផ្លូវជាតិលេខ៥(បាត់ដំបង-ស៊ីសុផុន)និងផ្លូវវាងក្រុង	405.000		4.050	81.000	85.050
ការស្តារផ្លូវជាតិលេខ៥(ព្រែកក្តាម-ធ្លាម្អម)និងផ្លូវវាងខេត្តកំពង់ឆ្នាំង	607.500		4.050	40.500	44.550
គម្រោងស្តារឡើងវិញផ្លូវជាតិលេខ៤៨ ដោយសាងសង់ទូលនៃលនិងស្ពាន	202 500	8.100	12.150	60.750	81 000
គម្រោងស្តារហេដ្ឋារចនាសម្ព័ន្ធបង្កដោយគ្រោះទឹកជំនន់នាឆ្នាំ២០១១	72.900	16.200	8.100		24.300
គម្រោងស្តាប្រឡាយទន្លេ	18.225	4.050	4.050	4.050	12.150
សាងសង់ស្ពានតាមបណ្តោយផ្លូវជាតិលេខ៧៣	60.750	4.050	8.100	32.400	44.550
ការស្តាបនាឡើងវិញផ្លូវជាតិលេខ៧៦អា(បានលុង-តាវែង)	202 500	4.050	8.100	40.500	52.650
ស្តារផ្លូវជាតិលេខ១៣ភ្ជាប់ពីផ្លូវជាតិលេខ៨និងលេខ១(កំចាយមារ- ប្រសូត)និងផ្លូវលេខ៣១៤ដេ(ប្រសូត-ព្រៃរំ-ព្រំដែនកម្ពុជានិងវៀតណាម)	81.000	4.050	8.100	20.250	32.400
ស្តារផ្លូវជាតិលេខ១១	405.000	4.050	12.150	81.000	97.200
គម្រោងសាងសង់ផ្លូវពីទន្លេបិទដល់ព្រែកតាម៉ាក់	272.158	4 050	8.100	81.000	93.150
ចម្រោះទឹកកខ្វក់នៅក្នុងទីក្រុងបួនគឺ: បាវិត ស្វាយរៀង បាត់ដំបង និងប៉ោយប៉ែត	60.750	4.050	8.100	32.400	44.550
ប្រព័ន្ធចម្រោះទឹកកខ្វក់ក្នុងខេត្តបន្ទាយមានជ័យ ក្នុងទីក្រុងកំពង់ឆ្នាំងខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកំពង់ធំ និងខេត្តសៀមរាប	202.500	4.050	8.100	40.500	52.650
ចម្រោះទឹកកខ្វក់នៅក្នុងភាគខាងជើងនៃរាជធានីភ្នំពេញ	60.750	8.100	20.250	32.400	60.750
ប្រព័ន្ធទឹកសំអុយនៅភាគខាងត្បូងនៃរាជធានីភ្នំពេញ	60.750	8.100	20.250	32 400	60 750
គម្រោងស្តាបនាផ្លូវវាងរាជធានីភ្នំពេញ	607.500	4.050	8.100	60.750	72.900
គម្រោងសាងសង់ផ្លូវដែកអាស៊ាន២៥៥ គ.ម(ភ្នំពេញ-ព្រំប្រទល់វៀតណាម)	2 025.000		4.050	60 750	64 800
ក្រសួងអភិវឌ្ឍន៍ជនបទ	585.593	184.180	135.653	73.183	393.016
គម្រោងមានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	546.044	169.574	123.254	60.640	353.467
គម្រោងស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយព្យុះកេតសាណា	162 000	77 760	19.290		97 050
គម្រោងកែលម្អផ្លូវជនបទ១	279 450	68 850	81 000	49 208	199 058
គម្រោងផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទជំហានទី២	104 594	22 964	22 964	11 433	57 360
គម្រោងមិនទាន់មានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	39.549	14.607	12.399	12.543	39.549

សម្គាល់: តម្លៃប៉ាន់ស្មានពីក្រសួង-ស្ថាប័ន ។ ប្រភពព័ត៌មាន: ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ទំព័រ ៦/១០

ការគ្រប់គ្រងឆ្នាំ២០១៣

តារាង "គ១"

ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

ឈ្មោះគម្រោង	តម្លៃគម្រោង	កម្រិតទុនវិនិយោគបែកតាមឆ្នាំ			
		២០១៣	២០១៤	២០១៥	សរុប៣ឆ្នាំ
មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍	3.098	1.033	1.033	1.033	3.098
បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនិងស្រាវជ្រាវជនជាតិដើមភាគតិច	7.874	3.562	2.185	2.126	7.874
សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ	7.108	2.369	2.369	2.369	7.108
ការអប់រំក្រៅប្រព័ន្ធ	765	255	255	255	765
ប្រព័ន្ធស្រោចស្រពខ្នាតតូច	11.178	4.212	3.382	3.584	11.178
ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ	3.281	1.094	1.094	1.094	3.281
អភិវឌ្ឍភូមិ	6 245	2.082	2.082	2.082	6.245
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	**208.964**	**80.388**	**62.265**	**66.311**	**208.964**
គម្រោងមានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**36.450**	**12.150**	**12.150**	**12.150**	**36.450**
សាងសង់ភូមិកុមារអេស អូ អេស នៅខេត្តក្រចេះ ព្រៃវែង និងខេត្តព្រះសីហនុ	36.450	12.150	12.150	12.150	36.450
គម្រោងមិនទាន់មានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**172.514**	**68.238**	**50.115**	**54.161**	**172.514**
សាងសង់និងអភិវឌ្ឍលំនៅដ្ឋានសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ	5.144	1.705	1.701	1.737	5.144
សាងសង់មណ្ឌលទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស	830	425	227	178	830
សាងសង់មជ្ឈមណ្ឌលសំចតនិងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្សនិងជនងាយរងគ្រោះ	1.268	648	620		1.268
សាងសង់អគារការិយាល័យសង្គមកិច្ចចំនួន១៥០ស្រុក	15.188	5.063	5.063	5.063	15.188
សាងសង់មជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះដោយការជួញដូរមនុស្សកោះរ៉ុង្វែល	648	413	126	109	648
សាងសង់មជ្ឈមណ្ឌលជាតិនៃជនពិការ	12.150	8.465	1.944	1.742	12.150
សាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន	20.250	4.050	4.050	12.150	20.250
សាងសង់វិទ្យាស្ថានជាតិសង្គមកិច្ច	6.723	2.357	2.163	2.203	6.723
សាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ	11 129	5.083	3.200	2 847	11.129
កសាងភូមិអភិវឌ្ឍអតីតយុទ្ធជនខេត្តមណ្ឌលគិរីនិងរតនគិរី	11.534	5.229	3.301	3.005	11.534
កសាងភូមិអភិវឌ្ឍអតីតយុទ្ធជនខេត្តពោធិសាត់ បាត់ដំបង ក្រចេះ និងខេត្តកំពង់ធំ	22.259	10 129	6.290	5.840	22.259
សាងសង់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទានិងបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការខេត្តស្ទឹងត្រែង	3 706	2.147	1 478	81	3 706
សាងសង់មជ្ឈមណ្ឌលយុវនីតិសម្បទា	7 825	4 617	1.993	1 215	7 825
និរន្តរភាពមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាទាំង១២	53 861	17 909	17 962	17 990	53 861
[illegible]	**341.542**	**38.900**	**30.254**	**36.065**	**105.219**
គម្រោង[illegible]ហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	9.421	3.321	972	81	4.374
[illegible]ទីផ្សារលក់ផលិតផលរបស់ប្រជាពលរដ្ឋក្រីក្រនៅខេត្តកំពង់ធំ	7 695	3.240	891		4 131
អភិវឌ្ឍ[illegible]ស្ទឹងជីនិត	1.726	81	81	81	243

24/29 ប្រភព: តម្លៃជាក់ស្តែងពីក្រសួង-ស្ថាប័ន ។ ប្រភពព័ត៌មាន.ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

 Kol

p

ការគ្រប់គ្រងឆ្នាំ២០១៣

តារាង "គ១"

ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា: លានរៀល

ឈ្មោះគម្រោង	តម្លៃគម្រោង	កម្រិតទុនវិនិយោគចែកតាមឆ្នាំ			
		២០១៣	២០១៤	២០១៥	សរុប៣ឆ្នាំ
គម្រោងមិនទាន់មានហិរញ្ញប្បទាន (គម្រោងវិនិយោគជាទុន)	**332.121**	**35.579**	**29.282**	**35.984**	**100.845**
ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យទេសចរណ៍នៅក្នុងក្របខណ្ឌអនុតំបន់ទន្លេមេគង្គ	170 100	8.100	8.100	16.200	32.400
ការអភិវឌ្ឍមេណ៍យដ្ឋានទឹកធ្លាក់ប៊ូស្រា	8 100	3.989	2.450	1.661	8.100
អភិវឌ្ឍមេណ៍យដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង	6075	2.430	2 126	1.519	6.075
ការអភិវឌ្ឍទេសចរណ៍ដើម្បីកាត់បន្ថយភាពក្រីក្រតាមច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង	5 670	2.025	1.620	2.025	5.670
ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តភាព	8.100	2.835	2.835	2 430	8.100
ពិពិធកម្មផលិតផលទេសចរណ៍នៅតំបន់អាទិភាពទាំង៥	69.276	8.100	4.050	4.050	16.200
ការសាងសង់វិទ្យាស្ថានស្រាវជ្រាវទេសចរណ៍	40.500	4.050	4.050	8.100	16.200
សាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលទេសចរណ៍	24.300	4.050	4.050		8.100
ក្រសួងធនធានទឹកនិងឧតុនិយម	**8.642.591**	**760.890**	**1.096.064**	**1.019.385**	**2.876.338**
គម្រោងមានហិរញ្ញប្បទាន (គម្រោងវិនិយោគជាទុន)	**7.788.045**	**713.707**	**1.044.831**	**950.130**	**2.708.668**
អភិវឌ្ឍធនធានទឹកស្ទឹងពោធិ៍សាត់ស្ទឹង ទី១និងទី២	302.738	40.379	161.474	40.338	242.190
គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រកង្កតដំណាក់កាលទី១	202.144	33.170	21.858		55.027
គម្រោងការពារទឹកជំនន់នៅទន្លេកំពង់ត្របែកខេត្តព្រៃវែង	125 607	11.502	14.540		26.042
អភិវឌ្ឍទំនប់មង្គលបុរីខេត្តបន្ទាយមានជ័យ	97.018	38.070	20 108		58.178
អភិវឌ្ឍប្រព័ន្ធធារាសាស្ត្រភាគពាយ័ព្យ	125 024	23.652	23.652		47.304
ស្តារហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពនៅបុព៌ានិងឆ្លៀសានដំណាក់កាលទី១និងទី២	178.200	16.200	20 068		36.268
កែលម្អនិងស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រនិងប្រព័ន្ធដោះទឹកភាគខាងលិចបឹងទន្លេសាប	220 636	4.406	4.022	6.917	15.345
កសិកម្មខ្នាតតូចនិងគាំពារសង្គមតាមបណ្តាខេត្ត	24.300	8.100	8.100		16.200
អភិវឌ្ឍធនធានទឹកស្ទឹងកែវ	172.603	32.400	1.288		33.688
អភិវឌ្ឍប្រព័ន្ធស្រោចស្រពស្ទឹងសែនខេត្តកំពង់ធំ	1.441.800	36.450	40.500	44.550	121.500
ជួសជុលអាងទឹកស្ទឹងស្រែងខេត្តសៀមរាប	221.875	41.796	42.067		83 863
អភិវឌ្ឍអាងទឹកតាសាល	121.500	12.150	12 150	16.200	40.500
គម្រោងអភិវឌ្ឍន៍ទំនប់ទឹកស្ទឹងពោធិ៍សាត់ទំនប់ទី៣និងទី៥ដំណាក់កាលទី១	269.151	60 750	48 600	48.762	158.112
គម្រោងស្តារភាពនៃការស្រោចស្រពតំបន់បឹងទន្លេសាប	113.400	22 583	7 970	4 925	35 478
គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូដំណាក់កាលទី១	423.347	40 500	40.500	40 500	121 500
[illegible]ប្រព័ន្ធស្រោចស្រពនៅខេត្តកំពត ខេត្តតាកែវ និងខេត្តកំពង់ធំ	54 270	12 150	12 150	12 150	36 450
គម្រោង[illegible]គ្រប់គ្រងធនធានទឹក	174 474	8 100	8 100	8 100	24.300
[illegible]វិស័យគ្រប់គ្រងធនធានទឹក	81 000	12 150	12 150	4.050	28 350
អភិវឌ្ឍប្រព័ន្ធស្រោចស្រព[illegible]ចាំង	182 250	32 400	32 400	36.450	101 250

កំណត់សម្គាល់: តម្លៃបាន់ស្មានពីក្រសួង ស្ថាប័ន ។ ប្រភពពីតំមាន ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណ ក្រសួងផែនការ

p

ករគ្រប់គ្រងឆ្នាំ២០១៣

តារាង "គ១"

ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

ឈ្មោះគម្រោង	តម្លៃគម្រោង	កម្រិតទុនវិនិយោគចែកតាមឆ្នាំ			
		២០១៣	២០១៤	២០១៥	សរុប៣ឆ្នាំ
អភិវឌ្ឍទំនប់ពហុបំណងដូនទ្រីខេត្តបាត់ដំបង	186.098	52.650	52.650	52.650	157 950
កែលម្អនិងស្តារឡើងវិញប្រព័ន្ធស្រោចស្រពនិងប្រព័ន្ធដោះទឹកកណ្តាលស្ទឹង-បាទី	101.250	40.500	32.400	28.350	101 250
ការគ្រប់គ្រងធនធានទឹកបានពីទន្លេមេគង្គ	60.750	12.150	16.200	16.200	44 550
ជួសជុលទំនប់អាងទឹកសាលាតាអនខេត្តបាត់ដំបង	93.150	4.050	4.050	4.050	12 150
កសិកម្មខ្នាតតូចនិងគាំពារសង្គមដំហានទី២	23.895	6.075	8.910	8.910	23.895
ការអភិវឌ្ឍធនធានទឹកស្ទឹងជីក្រែង	344.250		32.400	64.800	97.200
អភិវឌ្ឍទំនប់ផ្នែកខាងលើស្ទឹងព្រែកត្នោត	94.673	14.175	26.325	35 543	76.043
អភិវឌ្ឍធនធានទឹកស្ទឹងពោធិ៍សាត់	202.500	12.150	60.750	97.200	170.100
អភិវឌ្ឍពហុបំណងស្ទឹងសង្កែទំនប់បាត់ដំបង១	405.000	40.500	40.500	81.000	162.000
អភិវឌ្ឍប្រព័ន្ធធារាសាស្ត្រស្ទឹងស្វាស្លាប់	64.395	12.150	12.150	15.795	40.095
អភិវឌ្ឍធនធានទឹកស្ទឹងស្ទោង	202.500	32.400	40.500	48.600	121.500
អភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងការពារទឹកជំនន់ស្ទឹងសៀមរាប	283.500		40.500	40.500	81.000
អភិវឌ្ឍធនធានទឹកស្ទឹងស្រែងដំហានទី២	243.000		60.750	60.750	121.500
អភិវឌ្ឍធនធានទឹកស្ទឹងស្ទោងដំហាន២	243.000		4.050	4.050	8.100
អភិវឌ្ឍទំនប់ទឹកស្ទឹងពោធិ៍សាត់ទំនប់ទី៣និងទី៥ដំហានទី២	222.750			44.550	44.550
អភិវឌ្ឍប្រព័ន្ធស្រោចស្រពវ៉ៃកូដំហានទី២	486.000		81.000	84.240	165.240
គម្រោងមិនទាន់មានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**854.546**	**47.183**	**51.233**	**69.255**	**167.670**
គម្រោងអភិវឌ្ឍន៍ពង្រីកប្រព័ន្ធធារាសាស្ត្រកង្កត់ដំហានទី២	130.544	4.050	4.050	8.100	16.200
ស្តារព្រែកនាំជីល្បាប់	40.500	4.050	4.050	4.050	12.150
រៀបចំប្រព័ន្ធស្រោចស្រពកំពីងពួយ	20.250	4.050	4.050	8.100	16.200
ជួសជុលប្រព័ន្ធធារាសាស្ត្រអន្លង់	39.957	4.050	4 050	8.100	16.200
ជួសជុលប្រព័ន្ធធារាសាស្ត្របាយ័នកោ	12.555	4.050	4 050	4.455	12.555
ស្តារនិងកែលម្អប្រឡាយមេចេញពីស្ថានីយ៍បូមទឹក៨៥កន្លែង	13.365	4 050	4 050	5.265	13 365
ជួសជុលអាងទឹកព្រៃនប់ខេត្តព្រះសីហនុ	6.075	2.025	2 025	2.025	6.075
ជួសជុលប្រព័ន្ធធារាសាស្ត្រតាកែវ	196.425	4 050	4.050	4 050	12 150
ស្តារបណ្តាញស្ថានីយ៍ជលសាស្ត្រ៣០កន្លែង	2.025	608	608	810	2 025
ស[illegible]ធារាសាស្ត្រខ្នាតតូច១២៣ខេត្ត	271.350	4 050	4 050	4 050	12 150
អភិវឌ្ឍ[illegible]តូច	48 600	8 100	12 150	16 200	36 450
អភិវឌ្ឍ[illegible]ស្រោចស្រពអាង[illegible]កស្ទឹងស្លាគូ	72 900	4 050	4 050	4 050	12 150
ក្រសួង[illegible]	4.050	425		.	425

ការគ្រប់គ្រងឆ្នាំ២០១៣

តារាង "គ១"

ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា: លានរៀល

ឈ្មោះគម្រោង	តម្លៃគម្រោង	កម្រិតទុនវិនិយោគបែកតាមឆ្នាំ			
		២០១៣	២០១៤	២០១៥	សរុប៣ឆ្នាំ
គម្រោងមានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**4.050**	**425**			425
គម្រោងលើកកម្ពស់សុវត្ថិភាពនិយោជិតស្ត្រីនៅក្នុងឧស្សាហកម្មស្រាបៀរ	4.050	425			425
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីននិងសង្គ្រោះជនពិការដោយសារមីន	**1.058.200**	**79.218**	**77.598**	**79.623**	**236.439**
គម្រោងមានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**1.058.200**	**79.218**	**77.598**	**79.623**	**236.439**
គម្រោងបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម	1.058.200	79.218	77.598	79.623	236.439
គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ	**12.150**	**5.798**	**2.899**		**8.697**
គម្រោងមានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**12.150**	**5.798**	**2.899**		**8.697**
គម្រោងស្តារនិងសាងសង់ឡើងវិញបន្ទាប់ពីព្យុះកេតសាណា	12.150	5.798	2.899		8.697
ស្ថាប័នប្រឆាំងអំពើពុករលួយ	**17.010**	**6.804**	**6.804**	**3.402**	**17.010**
គម្រោងមិនទាន់មានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**17.010**	**6.804**	**6.804**	**3.402**	**17.010**
ពង្រឹងស្ថាប័នប្រឆាំងអំពើពុករលួយ	17.010	6.804	6.804	3.402	17.010
រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	**309.845**	**64.347**	**102.087**	**74.561**	**240.995**
គម្រោងមិនទាន់មានហិរញ្ញប្បទាន(គម្រោងវិនិយោគជាទុន)	**309.845**	**64.347**	**102.087**	**74.561**	**240.995**
ការកែលម្អព្រលានយន្តហោះខេត្តក្រចេះ	26.325	6.963	11.636	7.726	26.325
សាងសង់អាកាសយានដ្ឋាន	92.725	24.525	40.985	27.215	92.725
សាងសង់អាកាសយានដ្ឋាន	92.340	9.430	15.750	10.460	35.640
ការកែលម្អព្រលានយន្តហោះខេត្តព្រះវិហារ	34.425	9.106	15.216	10.104	34.425
ការកែលម្អព្រលានយន្តហោះខេត្តស្ទឹងត្រែង	23.531	6.224	10.400	6.906	23.531
សាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរណ៍ស៊ីវិល	40.500	8.100	8.100	12.150	28.350

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ការគ្រប់គ្រងឆ្នាំ២០១៣

តារាង"គ២"

ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស

គម្រោងឥណទាននិងឥណទានភ្ជាប់សន្យា

ឯកតា:លានរៀល

ក្រសួង ស្ថាប័ន	សរុបគម្រោងឥណទាន (១)+(២)	សរុបឥណទានភ្ជាប់សន្យា (១)+(២)x៦០%*	គម្រោងមានហិរញ្ញប្បទាន (១)	គម្រោងមិនទាន់មានហិរញ្ញប្បទាន (២)
សរុបរួម	**3.576.579**	**3.312.620**	**2.916.653**	**659.926**
វិស័យរដ្ឋបាលទូទៅ	**265.211**	**227.080**	**169.863**	**95.348**
០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី	85.016	85.020	85.016	
០៧.២. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ	44.181	26.510		44.181
១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	101.048	94.570	84.848	16.200
២៦. ក្រសួងយុត្តិធម៌	28.162	16.900		28.162
៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ	6.804	4.080		6.804
វិស័យសង្គមកិច្ច	**160.810**	**106.090**	**24.012**	**136.798**
១១. ក្រសួងព័ត៌មាន	10.125	6.080		10.125
១២. ក្រសួងសុខាភិបាល	3.200	1.920		3.200
១៦. ក្រសួងអប់រំ យុវជន និងកីឡា	20.852	13.680	2.916	17.936
១៨. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	3.767	2.260		3.767
១៩. ក្រសួងបរិស្ថាន	8.927	8.760	8.522	405
២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	80.388	53.090	12.150	68.238
២៣. ក្រសួងធម្មការនិងសាសនា	13.669	8.200		13.669
២៤. ក្រសួងកិច្ចការនារី	425	420	425	
៣២. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	19.459	11.680		19.459
វិស័យសេដ្ឋកិច្ច	**3.150.559**	**2.979.450**	**2.722.777**	**427.781**
០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	64.347	38.610		64.347
១៣. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	241.636	228.170	207.968	33.668
១៥. ក្រសួងពាណិជ្ជកម្ម	10.935	6.560		10.935
១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	1.016	610		1.016
២០. ក្រសួងអភិវឌ្ឍន៍ជនបទ	184 180	178 340	169 574	14.607
២២. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	93 911	84 190	69 611	24 300
២៥. ក្រសួងសាធារណការនិងដឹកជញ្ជូន	1 745.711	1 667.250	1.549 564	196.146
២៧. ក្រសួងទេសចរណ៍	38 900	24.670	3 321	35.579
២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	9 032	9 030	9.032	
២៩. ក្រសួងធនធានទឹកនិងឧតុនិយម	760.890	742 020	713 707	47 183

សម្គាល់: (*) ឥណទានភ្ជាប់សន្យាត្រូវបានកំណត់យកលេខគត់

ការគ្រប់គ្រងឆ្នាំ២០១៣

តារាង "ឃ"

ចំណាយមូលធនថវិកាថ្នាក់ជាតិ

ឥណទានភ្ជាប់សន្យានិងឥណទានទូទាត់

ឯកតា: លានរៀល

ក្រសួង ស្ថាប័ន	សរុប ឥណទានភ្ជាប់សន្យា	សរុប ឥណទានទូទាត់	ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស: ឥណទានភ្ជាប់សន្យា=ឥណទានទូទាត់			ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស		ការទូទាត់ប្រាក់កម្ចី
			គម្រោងវិនិយោគ	បដិភាគវិនិយោគ	មូលនិធិទ្រទ្រង់ថវិកា	ឥណទានភ្ជាប់សន្យា	ឥណទានទូទាត់	ឥណទានភ្ជាប់សន្យា=ឥណទានទូទាត់
សរុបរួម	**5.049.120**	**4.882.500**	**951.500**	**220.000**	**285.000**	**3.312.620**	**3.146.000**	**280.000**
វិស័យរដ្ឋបាលទូទៅ	**227.080**	**215.650**				**227.080**	**215.650**	
០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី	85.020	80.740				85 020	80.740	
០៧.២. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ	26.510	25.180				26.510	25.180	
១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	94.570	89.810				94.570	89.810	
២៦. ក្រសួងយុត្តិធម៌	16.900	16.050				16.900	16.050	
៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ	4.080	3.870				4.080	3.870	
វិស័យសង្គមកិច្ច	**106.090**	**100.750**				**106.090**	**100.750**	
១១. ក្រសួងព័ត៌មាន	6.080	5.770				6.080	5.770	
១២. ក្រសួងសុខាភិបាល	1.920	1.820				1.920	1.820	
១៦. ក្រសួងអប់រំ យុវជន និងកីឡា	13.680	12.990				13.680	12.990	
១៨. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	2.260	2.150				2.260	2.150	
១៩. ក្រសួងបរិស្ថាន	8.760	8.320				8.760	8.320	
២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	53.090	50.420				53.090	50.420	
២៣. ក្រសួងធម្មការនិងសាសនា	8.200	7.790				8.200	7.790	
២៤. ក្រសួងកិច្ចការនារី	420	400				420	400	
៣២. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	11.680	11.090				11.680	11.090	
វិស័យសេដ្ឋកិច្ច	**3.404.450**	**3.254.600**	**425.000**			**2.979.450**	**2.829.600**	
០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	38.610	36.670				38.610	36.670	
១៣. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	228.170	216.690				228.170	216.690	
១៥. ក្រសួងពាណិជ្ជកម្ម	6.560	6.230				6 560	6.230	
១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	20.610	20.580	20.000			610	580	
២០. ក្រសួងអភិវឌ្ឍន៍ជនបទ	278.340	269.370	100.000			178.340	169.370	
២២. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	84.190	79 960				84.190	79 960	
២៥. ក្រសួងសាធារណការនិងដឹកជញ្ជូន	1.872 250	1 788 390	205 000			1.667 250	1 583 390	
២៧. ក្រសួងទេសចរណ៍	24.670	23 430				24.670	23 430	
២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	9.030	8 580				9 030	8.580	
២៩. ក្រសួងធនធានទឹកនិងឧតុនិយម	842.020	804 700	100 000			742 020	704 700	
ចំណាយមិនទាន់បែងចែក	**1.311.500**	**1.311.500**	**526.500**	**220.000**	**285.000**			**280.000**
- ការទូទាត់ប្រាក់កម្ចី	280 000	280 000						280 000
- គម្រោងវិនិយោគ	526 500	526 500	526 500					
- បដិភាគវិនិយោគ	220.000	220 000		220 000				
- មូលនិធិទ្រទ្រង់ថវិកា	285 000	285 000			285 000			

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិ ថ្នាក់ **នាយឧត្តមសេនីយ៍ផ្កាយមាស ៤** ជូន នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប :

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុល សាវ៉ន្ត** អត្តលេខ ០០០០៥២

២-ឯកឧត្តមឧត្តមសេនីយ៍ឯក **នៅ សំ** អត្តលេខ ០០០០៦២

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣៣. ១២.១២. ១០៦៣

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១២

...ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

... សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និង មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ ចំនួន ១៦ រូប មានគុណបំណាច់ ក្នុងការចូលរួមជួយឧបត្ថម្ភ ថវិកា និង សម្ភារៈ កសាងអភិវឌ្ឍន៍អង្គភាព កងពលតូចអន្តរាគមន៍លេខ ១៤ កន្លងមក

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១- លោកសាស្ត្រាចារ្យមហាបណ្ឌិត ភ្លាត់ យុទ្ធស្លា
២- លោក ស្រ៊ុន អង្គរ៉េង
៣- លោក ហេង ណារិទ្ធ
៤- លោក សេក តេនៈ
៥- លោក ឆង់ សុខហេង
៦- លោក អ៊ុម លក្ខិណា

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

លោក ព្រាប មុនន្ធិ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១- លោក ស៊ុន ធីរ៉ូ
២- លោក ធីក ថាវត្ត
៣- លោក កាន់ សុភាព
៤- លោក ជា ចន្ទ្រា
៥- លោក ទឹម ធារៈ
៦- លោក ទូច ម៉ាជូទិ
៧- លោក ខូច ម៉េងថៃ

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- លោក សុត សុចិត្ថា
២- លោក សេក សារឹម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ល.ខ ១០៣៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ... ឆ្នាំ២០១២
... ទីស្តីការគណៈរដ្ឋមន្ត្រី ...
... សុខា

ជាលេ.១២១២.១០៦៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និង នាយទាហាន ចំនួន០៦រូប មានគុណបំណាច់ក្នុងការជួយឧបត្ថម្ភ
ថវិកា និង សម្ភារៈ កសាងអភិវឌ្ឍន៍អង្គភាព តំបន់ប្រតិបត្តិការសឹករងព្រះសីហនុ កន្លងមក

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍

១- ឯកឧត្តម ង្វៀន វ៉ាន់នុ៉ក NGUYEN VANNUK
២- លោកជំទាវ ឡេធី អាយណាម LE THI AI NAM
៣- ឧត្តមសេនីយ៍ត្រី ហោ ខៃណាម HO KHAI NAM
៤- វរសេនីយ៍ឯក ង្វៀន តឹនវ៉ាន់ NGUYEN TAN VAN
៥- វរសេនីយ៍ឯក អ៊ុក វណ្ណា អត្តលេខ ០០៥៩០៧
៦- វរសេនីយ៍ឯក ឈុំ វិសាល អត្តលេខ ០១០៥៦៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/១២១២/១០៦៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១២

លេខៈ១០៣៥០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុំ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានយោធភូមិភាគទី៩ នៃកងទ័ពប្រជាជនវៀតណាម ចំនួន ០៣រូប មានគុណបំណាច់ និងស្នាដៃល្អ ក្នុងការបង្ហាត់បង្រៀន ដល់សិក្ខាកាម វគ្គបំប៉ន ជំនាញជួសជុលរថពាសដែក នៅយោធភូមិភាគទី៥ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

- វរសេនីយ៍ឯក **ហា ទួនគួន** HA TUAN QUAN

ខ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

១- វរសេនីយ៍ឯក **ត្រឹន ហុងថាង** TRAN HUNG THANG

២- វរសេនីយ៍ទោ **ត្រឹន ហុងខាញ់** TRAN HUNG KHANH

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធាកសា. ១៤.១២.១០៣៦

លេខ: ១០៣៦ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១២

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២
អគ្គលេខាធិការរងទី១ ... រដ្ឋាភិបាល

... សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់គ្រប់គ្រងក្រុមហ៊ុន ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងការកសាងរោងចក្រផលិតខ្សែអគ្គិសនី និងគ្រឿងអេឡិចត្រូនិច រួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចកម្ពុជា

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា
លោក ស៊ីនជី យ៉ាហ្សាគី (SHINJI YAZAKI)
ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ
លោក ផាត់ ប៊ុនហួរ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ១០៣៤ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

សរល. ១២១២.១០៦៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយ ឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិជាករណីពិសេស ជូនមន្ត្រីរាជការ ចំនួន ០១ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានដូចខាងក្រោម :

ល.រ	គោត្តនាមនិងនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់	
			ចាស់	ថ្មី
១	លីម គឹមហេង	ប	វរមន្ត្រី ថ្នាក់លេខ ៨	ឧត្តមមន្ត្រី ថ្នាក់លេខ ៦

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

មាត្រា ២ : ប្តូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការ ចំនួន ១០ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានដូចខាងក្រោម:

ល.រ	គោត្តនាមនិងនាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ថ្មី
១	យី ចន្ទមុន្នី	ប	ពីនាយក្រមការ ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ៦
២	ឆេត ធីរៈ	ប	ពីនាយក្រមការ ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ៦
៣	ស គន្ធា	ប	ពីនាយក្រមការ ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ៦
៤	ហុង ប៊ុនធី	ប	ពីនាយក្រមការ ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ៦
៥	មាស ចំរើន	ប	ពីនាយក្រមការ ថ្នាក់លេខ ២	ទៅអនុមន្ត្រី ថ្នាក់លេខ ៧
៦	គ្រាក់ សៀវអាន	ប	ពីនាយក្រមការ ថ្នាក់លេខ ៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១០
៧	ញ៉ាន ធិត្យចិន្តា	ប	ពីនាយក្រមការ ថ្នាក់លេខ ៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១០
៨	កែច ធុន្នី	ប	ពីនាយក្រមការ ថ្នាក់លេខ ៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១០
៩	ឆេន ច័ន្ទចរិទ្ធ	ប	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៥	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១០	សេង សុធី	ប	ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៥	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

លេខ:១០៧៣ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ចន្ទ. ១២.១២. ១០៧៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និងមន្ត្រីរាជការចំនួន ២២រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានាលើវិស័យគ្រប់វិស័យ នៅក្នុងខេត្តព្រះសីហនុ

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោកវរសេនីយ៍ឯក ខាឡូ ម៉ូរ
២-លោកវរសេនីយ៍ទោ សាក់ សុវណ្ណ
៣-លោកវរសេនីយ៍ត្រី ស្រេង សុខា
៤-លោកអនុសេនីយ៍ឯក សារិន្ទ សំណាង
៥-លោកអនុសេនីយ៍ឯក ឯក ស៊ីផួន
៦-លោកអនុសេនីយ៍ឯក នៅ សុខា
៧-លោកអនុសេនីយ៍ឯក ម៉ៅ ស៊ីង
៨-លោកអនុសេនីយ៍ទោ គួច ចាន់ប៊ុនលី
៩-លោកអនុសេនីយ៍ទោ ខួន ស៊ីថា
១០-លោកអនុសេនីយ៍ទោ ពៅ សុផាត

ROYAUME DU CAMBODGE

ខ- គ្រឿងឥស្សរិយយសស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១-លោកវរសេនីយ៍ទោ **អ៊ាង ភារៈ**

២-លោកវរសេនីយ៍ត្រី **ខៀម សៅ**

៣-លោកវរសេនីយ៍ត្រី **គង់ ធឿន**

៤-លោកអនុសេនីយ៍ឯក **ឈុប សារិម**

៥-លោកអនុសេនីយ៍ឯក **ឆាយ ពុធផល្លា**

៦-លោកអនុសេនីយ៍ទោ **ហេង សុវណ្ណ**

គ- គ្រឿងឥស្សរិយយសស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១-លោកឧត្តមសេនីយ៍ត្រី **ផន គីរីវណ្ណា**

២-លោកវរសេនីយ៍ត្រី **ឌិន ប្រូសិទ្ធ**

៣-លោកអនុសេនីយ៍ឯក **ផាង សូចឡេ**

៤-លោកអនុសេនីយ៍ឯក **ឌី មេឃជន**

៥-លោក **ជ័យ ជនតារា**

៦-លោក **ឃ៉ង សារ៉ាដែន**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២

លេខៈ ១០៣៩ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

...សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ដល់ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ៖

១-វរសេនីយ៍ឯក **សុខ វិជ្ជួល** អត្តលេខ ០០០៩៥៦
២-វរសេនីយ៍ឯក **សោម សាមិទ្ធ** អត្តលេខ ០០០៩៥០
៣-វរសេនីយ៍ឯក **ឆេត រួន** អត្តលេខ ០០១៤១៩
៤-វរសេនីយ៍ឯក **សួន មករ** អត្តលេខ ០០៣០២០
៥-វរសេនីយ៍ឯក **ម៉ាន់ ម៉េងអៀង** អត្តលេខ ០០៤២២៨
៦-វរសេនីយ៍ឯក **យួន សំខាន់** អត្តលេខ ០១០៣៣៥
៧-វរសេនីយ៍ឯក **ឃិន ម៉េងស្រេង** អត្តលេខ ០០២៧៣៤
៨-វរសេនីយ៍ឯក **អ៊ុក ចន្ធា** អត្តលេខ ០០៤៩៦៧
៩-វរសេនីយ៍ឯក **ព្រហ្ម ឆ៉ាត់** អត្តលេខ ០០៣៩៦៣
១០-វរសេនីយ៍ឯក **សាត់ សារ៉ាន** អត្តលេខ ០០២៧៣៤
១១-វរសេនីយ៍ឯក **អ៊ុក សាម៉ុន** អត្តលេខ ០០២៦៤០

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១២-វរសេនីយ៍ឯក **សេខ ឆារិន** អត្តលេខ ០៤៥៨៣៨

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពាសោ ១២១៧.១០៥០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១២

លេខ: ១៦៤០ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១២

អគ្គលេខាធិការរង[illegible]រដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ៖

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជា តែច** មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **មៅ សុផណ្ណ** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

រកត. ១២១២.១០៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២

លេខ: ១០៧៦ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១២

[illegible]ទទួលបន្ទុករាជរដ្ឋាភិបាល

[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: កាត់ផ្ទៃដីទំហំ ១.៨២០ ហិកតា នៅស្រុកទឹកជុស ខេត្តកំពង់ឆ្នាំង ពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ១០២០ច.ល

ចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

៣១៩. ១២១២. ១០៥២

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០៥៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៤៣៣៤,៦១ ហិកតា នៅស្រុកជ័យសែន និងស្រុកត្បែង ខេត្តព្រះវិហារ ពីតំបន់ព្រៃឈើ និងពីដីសម្បទានសេដ្ឋកិច្ច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៤៦ គ.គ្រ ដរខ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ដីសរុបទំហំ ៨៣៣៩,៦១ ហិកតា ដែលក្នុងនោះកាត់ចេញ (១) ទំហំ ៦៨,៥៣ ហិកតា ពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង(២) ទំហំ ១៦៨០.៨៧ ហិកតា ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (៣) ទំហំ ១៦៩១.០៥ ហិកតា ពីក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (៤) ទំហំ ៦៧.៣១ហិកតា ពីក្រុមហ៊ុន ឡាន ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (៥) ទំហំ ៨២៧.២៥ ហិកតា ពីក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត ដើម្បីធ្វើប្រទានកម្មទំហំ ៣៩៤០,១៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣៩៤,៨៨ ហិកតា រក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅខេត្តព្រះវិហារ ក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១.១ ភូមិតស៊ូ ឃុំតស៊ូ ស្រុកជ័យសែន៖

- ផ្ទៃដីទំហំ ៦៨,៥៣ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន១២គ្រួសារ
- ផ្ទៃដីទំហំ ៥៥៦,៨៦ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៥០៩,០៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១៣ គ្រួសារ និងដីទំហំ ៤៧,៨៩ ហិកតារក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។

p

១.២ ភូមិសំរោង ឃុំតស៊ូ ស្រុកជ័យសែនៈ

- ផ្ទៃដីទំហំ ១២២៣,៥១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ហេង រួយ (ខេមបូឌា) អិនធើណេសិនណល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១០៤៨,១៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២០៥ គ្រួសារ និងដីទំហំ ១៧៥,៣២ ហិកតារក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- ផ្ទៃដីទំហំ ១៦៩១,០៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អិនធើណេសិនណល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១៥៩៤,៩០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៩៦ គ្រួសារ និងដីទំហំ ៩៦,១៥ ហិកតា រក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- ផ្ទៃដីទំហំ ៦៧,៣១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ឡាន ហ្វេង (ខេមបូឌា) អិនធើណេសិនណល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៤ គ្រួសារ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

១.៣ ភូមិប្រើសក្តក ឃុំម្លូព្រៃពីរ ស្រុកឆែប៖

- ផ្ទៃដីទំហំសរុប ៨២៧,២៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន រួយ ហ្វេង (ខេមបូឌា) អិនធើណេសិនណល ខមភេនី លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្ម ទំហំ ៧៥២,១៣ ហិកតា ជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋចំនួន ១១៨ គ្រួសារ និងដីទំហំ ៧៥,១២ហិកតារក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៧៥៨គ្រួសារ នៅស្រុកជ័យសែន និងស្រុកឆែប ខេត្តព្រះវិហារ ស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១២៥ គ្រួសារ នៅភូមិតស៊ូ ឃុំតស៊ូ ស្រុកជ័យសែន
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៥១៥ គ្រួសារ នៅភូមិសំរោង ឃុំតស៊ូ ស្រុកជ័យសែន
- ប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋចំនួន ១១៨ គ្រួសារ នៅភូមិប្រើសក្តក ឃុំម្លូព្រៃពីរ ស្រុកឆែប ។

មាត្រា ៣ ..

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ចំនួន ៩៧៥ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៧៣៥ គ្រួសារ លើ ៩៧៣ ក្បាលដី កម្មសិទ្ធិរបស់គណបក្សប្រជាជន ០១ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ (ស្នាក់ការនគរបាល) ០១ ក្បាលដី ដែលស្ថិតនៅក្នុងភូមិ ដូចខាងក្រោម៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៣៧ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១២២ គ្រួសារ នៅភូមិតស៊ូ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៦៨៧ ក្បាលដី ជូនប្រជាពលរដ្ឋ ចំនួន ៥០៥ គ្រួសារ កម្មសិទ្ធិរបស់ការគណៈបក្សប្រជាជន ០១ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ (ស្នាក់ការនគរបាល) ០១ ក្បាលដី នៅភូមិសំរោង
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៥១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១០៨ គ្រួសារ នៅភូមិប្រើសក្អក ។

មាត្រា ៤ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៥ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ឧ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៥៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៤.៩៥៨ ហិកតា នៅស្រុកមេមត់ ខេត្តកំពង់ចាម ដែលក្នុងនោះ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងពីដីដែលមានដីការដកហូត ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៤១១ លខកច ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៤.៨៥៨ ហិកតា ដែលក្នុងនោះ ទំហំ ១.៤១៧ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងទំហំ ៣.៤៤១ ហិកតា ពីដីដែលមានដីកាដកហូត លេខ ០០៧/០៦.០០៩/០៦ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិចង្កុំទី១ ភូមិចង្កុំកណ្តាល ឃុំទន្លូង និង ភូមិឃ្សរ ឃុំជាំក្រវៀន ស្រុកមេមត់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៨១៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិចង្កុំទី១ ភូមិចង្កុំកណ្តាល ឃុំទន្លូង និង ភូមិឃ្សរ ឃុំជាំក្រវៀន ស្រុកមេមត់ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

p

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១៩ ខែ ៦ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៨៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៨ ៩០៤ ហិកតា នៅក្នុងស្រុកទឹកផុស ស្រុកបរិបូណ៌ និងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងរក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

p

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១០៧២ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៩០៧ ខ.ពស ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៨.៩០៤ ហិកតា ក្នុងនោះ (១) ទំហំ ១.៩២០ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ (២) ទំហំ ៦ ១៨៨ ហិកតា ពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច (៣)ទំហំ ៦៦៦ ហិកតា ពីស្ថានីយ៍កូនឈើម្យៅក្រដាស ហ៊ុន សែន មានក និង(៤) ទំហំ ២៣០ ហិកតា ពីដីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៧.៨៧៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១.០២៦ ហិកតារក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ ស្ថិតនៅក្នុងភូមិឃុំស្រុកដូចខាងក្រោម៖

- ផ្ទៃដីសរុបទំហំ ១ ១៦១ ហិកតា កាត់ចេញដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៩៥៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២០៧ ហិកតារក្សាទុកជាដីព្រៃបំរុងសម្រាប់សហគមន៍ព្រៃឈើ នៅក្នុងភូមិ រកាទង ឃុំទួលខ្ពស់ ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ៨៨៨ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៨៨៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងពុំមានរក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើនៅភូមិជីពូក ឃុំក្បាលទឹក ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ៩៧៦ ហិកតា ក្នុងនោះ ទំហំ ២១៦ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងទំហំ ២៦០ ហិកតា ពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៩២៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤៨ ហិកតា

p

រក្សាទុកជាដីបម្រុង សម្រាប់សហគមន៍ព្រៃឈើ នៅភូមិតាំងខ្យា ឃុំក្បាលទឹក ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ

- ផ្ទៃដីសរុបទំហំ ២៦៣៧ ហិកតា ក្នុងនោះ: (១) ទំហំ ១.០០២ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ទំហំ ១.៤០៥ ហិកតា កាត់ចេញពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និង(៣) ទំហំ ២៣០ ហិកតា ពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ២.៤៦៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៧០ ហិកតា រក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ នៅភូមិក្រសាំងដុះឡើង ឃុំក្បាលទឹក ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៤) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ១៧៨៧ ហិកតា ក្នុងនោះ: ទំហំ ១១៤ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងទំហំ ១.៦៧៣ ហិកតា ពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ១.៤៣៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣៤៨ ហិកតា រក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ នៅក្នុងភូមិក្តុល ឃុំក្រាំងស្គារ ស្រុកទឹកផុសតាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៥) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ១៦៨៩ ហិកតា កាត់ចេញដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១.៤៩៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៩៤ ហិកតា រក្សាទុកជាដីព្រៃបំរុងសម្រាប់ សហគមន៍ព្រៃឈើ នៅក្នុងភូមិ អញ្ចាញរូង ឃុំអញ្ចាញរូង ស្រុកបរិបូណ៌ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៦) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ៦៦៦ ហិកតា កាត់ចេញដីស្ថានីយកូនឈើម្សៅក្រដាស ហ៊ិន សែន មានកនិងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៦០៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥៩ ហិកតា រក្សាទុកជាដីព្រៃបំរុង សម្រាប់សហគមន៍ព្រៃឈើស្ថិតនៅក្នុងភូមិ មានកលិច ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៧) នៃអនុក្រឹត្យនេះ ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៣.០៧៨ គ្រួសារ នៅក្នុងស្រុកទឹកផុស ស្រុកបរិបូណ៌ និងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥០៣ គ្រួសារ នៅភូមិរកាទង ឃុំ ទូលខ្ពស់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៤ គ្រួសារ នៅភូមិជីពូក ឃុំក្បាលទឹក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៨ គ្រួសារ នៅភូមិតាំងខ្យា ឃុំក្បាលទឹក
